ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៩

# សេចក្តីប្រកាសព័ត៌មាន

ស្តីពីការតែងតាំងលោក **អាន់ឌ្រូ ធី ខេលៃ** ជាសហព្រះរាជអាជ្ញាអន្តរជាតិថ្មី

បន្ទាប់ពីត្រូវបានតែងតាំងដោយអគលេខាធិការអង្គការសហប្រជាជាតិ ឯកឧត្តម បាន គីមូន និងបន្ទាប់ពីទទួលបានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រម ព្រះមហាក្សត្រនរោត្តមសីហមុនី បានឡាយព្រះហស្តលេខាតែងតាំង លោក **អាន់ឌ្រូ ធី ខេលៃ** (Andrew T. Cayley) មកពីចក្រភពអង់គ្លេសជាសហព្រះរាជអាជ្ញា អន្តរជាតិថ្មី សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងលោក **នីកូឡាស គុមចាញ** (Nicholas Koumjian) មកពីសហរដ្ឋ អាមេរិក ជាសហព្រះរាជអាជ្ញាអន្តរជាតិបំរុង។

ក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ លោក **ខេលៃ** បានធ្វើជាមេធាវីការពារក្តីឯកជនឲ្យលោក ឆាល ធេល័រ ( Charles Taylor) នៅតុលាការពិសេសសម្រាប់ប្រទេស សេរ៉ា លីអូន និងលោក អ៊ី វ៉ាន ឃឺ ម៉ាក់ ( Ivan Cermak) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅអតីតប្រទេស យូហ្គោ ស្លាវី។

ពីឆ្នាំ ២០០៥ ដល់ ២០០៧ គាត់បានធ្វើជា អ្នកពិគ្រោះយោបល់ជាន់ខ្ពស់ ឲ្យតុលាការ ឧក្រិដ្ឋកម្មសង្គ្រាម (ICC) ក្នុងនាមជាកំរិតទទួលខុសត្រូវលើការស៊ើបអង្កេតនៅទីក្រុង ដា ហ្វ៊រ និងជាបន្តបន្ទាប់ ការស៊ើបអង្កេត សំនុំរឿងលើកដំបូងនៅទីក្រុងដា ហ្វ៊រ ប្រឆាំនឹង លោក អាម៉ាត់ ហារុន ( Amhmed Harun) និងលោក អាលី ខាសសៃ ( Aly Kushayb)។

ពីឆ្នាំ ២០០១ ដល់ ២០០៥ គាត់ធ្វើជាអ្នកប្រឹក្សាជាន់ខ្ពស់ឲ្យព្រះរាជអាជ្ញានៅតុលាការឧក្រដ្ឋកម្មអន្តរជាតិ សម្រាប់អតីត ប្រទេស យូ ហ្គូ ស្លាវី ។

នៅទីនោះ គាត់ទទួលខុសត្រូវ សម្រាប់ការស៊ើបអង្កេតបន្ត ប្រឆាំនឹងឧត្តមសេនីយ៍ រ៉ាត់ កូ ម្លាឌីក (Ratko Mladic) និងធ្លាប់បានដឹកនាំធ្វើការចោទប្រកាន់ជាអន្តរជាតិ លើកដំបូងទៅលើសមាជិកកងទ័ពទំដោះ កូស ស្វូ ។

លើសពីនេះទៅទៀត គាត់ធ្លាប់បំរើការងារជាអ្នក ផ្តល់ប្រឹក្សាយោបល់ឲ្យព្រះរាជអាជ្ញា នៅតុលាការឧក្រដ្ឋកម្មអន្តរជាតិ សម្រាប់អតីត ប្រទេស យូ ហ្គូ ស្លាវី ពីឆ្នាំ ១៩៩៥ ដល់ ២០០១ ហើយនៅក្នុងរយៈពេល៣ឆ្នាំដំបូង គាត់ធ្លាប់ជាមនុស្សទី២ របស់កងទ័ព អង់គ្លេស ក្រោមការិយាល័យកិច្ចការបរទេស និងប្រទេសរណប នៅតុលាការឧក្រដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេស យូ ហ្គូ ស្លាវី។

ជាបន្តបន្ទាប់គាត់ត្រូវបានគេជ្រើសរើសជាមនុស្សអចិន្ត្រៃយ៍ ប្រចាំនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេស យូ ហ្គូ ស្លាវី ក្នុងឆ្នាំ ១៩៩៨ ហើយនិង ធ្វើជាអ្នកប្រឹក្សាឲ្យព្រះរាជអាជ្ញា ក្នុងសវនាការចំនួន៥ ក្នុងរយៈ៦ឆ្នាំ ដោយរួមទាំងតុលាការលើកទី១ ទាក់ទងនឹងព្រឹត្តិការណ៍ក្នុងទីក្រុង ស្រ៊ី ប្រ៊ីនីកា ( Srebrenica) នៅខែ កក្កដា ឆ្នាំ ១៩៩៥។

លោក **ខេលៃ** មានសញ្ញាប័ត្របរិញ្ញាប័ត្រ និងអនុបណ្ឌិត ពីសាកលវិទ្យាល័យទីក្រុងឡុង និងជាមន្ត្រីជំនាញដែលមានសញ្ញាប័ត្រមកពី សាលាបណ្ឌិតសភាយោធា សែនឌឹស នៃប្រទេសអង់គ្លេស។

## សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង


លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
ទូរសារលេខ +855 (0) 23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារុំ**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
ទូរសារលេខ +855 (0) 23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org

លោកស្រី **យូកូ មេដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ: +855 (0) 12 488 319
ទូរស័ព្ទលេខ: +855 (0) 23 219 814 លេខបន្ត 6139
សារអេឡិចត្រូនិច: maeday@un.org